**សាលាដំបូងខេត្តតាកែវ**
សំណុំរឿងរដ្ឋប្បវេណីលេខ ៩២៨
ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៨
**សាលក្រមលេខ: ៦១(ក)**
**ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បង្កើតឡើងតាមច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកត/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

បានបើក នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០២១ វេលាម៉ោង ប្រាំបី និងសាមសិប នាទីព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**រវាងដើមចោទ** [redacted] មានទីស្នាក់ការផ្ទះ [redacted] ដោយមានលោក[redacted] ជាមេធាវីតំណាងដោយអាណត្តិ។

និងសហចុងចម្លើយ:

១.ឈ្មោះ [redacted] ច័ន្ទវាសនា ថ្ងៃខែឆ្នាំកំណើត ២៨.០៦.១៩៨៧ ភេទប្រុស សញ្ជាតិខ្មែរ

២.ឈ្មោះ [redacted] ភក្តី ថ្ងៃខែឆ្នាំកំណើត ០៥.០៣.១៩៨៨ ភេទស្រី សញ្ជាតិខ្មែរ និង

៣.ឈ្មោះ [redacted] ជានី អាយុ ៥៩ ឆ្នាំ ភេទស្រី

មានអាសយដ្ឋាននៅ[redacted]។

ដោយមានលោក [redacted] ជាសហមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ។

## <u>អង្គហេតុ និង ចំណុចវិវាទ</u>

### ១.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ៖

១.បង្គាប់ឲ្យសហចុងចម្លើយ សងប្រាក់ដើមដែលជំពាក់សរុបចំនួន ៩៦.០០០ (ប្រាំបួនម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

២.បង្គាប់ឲ្យសហចុងចម្លើយ សងការប្រាក់ក្នុងអត្រា ១,៥% ក្នុងមួយខែ លើប្រាក់ដើមជំពាក់ចំនួន ៩៦.០០០ (ប្រាំបួនម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ រហូតដល់ថ្ងៃសងរួចជាក់ស្តែង ។

៣.បង្គាប់ឲ្យសហចុងចម្លើយ សងការខូចខាត និងសំណងជំងឺចិត្តចំនួន ២០.០០០ (ពីរម៉ឺន)ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

៤.បង្គាប់ឲ្យសហចុងចម្លើយសងកម្រៃសេវាពឹងពាក់មេធាវីចំនួន១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

៥- សុំឲ្យប្រកាសថា សាលក្រមនេះមានអានុភាពអនុវត្តបណ្ដោះអាសន្ន។

៦. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

**២.អង្គហេតុសង្ខេបៈ**

-តាមពាក្យបណ្ដឹងចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ [redacted] បានបញ្ជាក់ថាៈ កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣ សហចុងចម្លើយឈ្មោះ [redacted] ច័ន្ទវាសនា និងប្រពន្ធឈ្មោះ [redacted] ភក្ដី បានចុះកិច្ចសន្យា សហប្រតិបត្តិការពាណិជ្ជកម្មជាមួយក្រុមហ៊ុន [redacted] អំពីការទទួលទិញ និងចែកចាយបន្តនូវផលិតផលប្រេងឥន្ធនៈរបស់ក្រុមហ៊ុន [redacted] នៅស្ថានីយ៍ប្រេងរបស់ខ្លួន ដែលមានទីតាំងស្ថិតនៅ [redacted] និង [redacted] ដែលមានទីតាំងស្ថិតនៅ [redacted]។ បន្ទាប់ពីចុះកិច្ចសន្យាសហប្រតិបត្តិការពាណិជ្ជកម្មហើយ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ចុងចម្លើយឈ្មោះ [redacted] ច័ន្ទវាសនា ដោយមានឈ្មោះ [redacted] ភក្ដី ធ្វើជាសាក្សី បានចុះកិច្ចសន្យាផ្គត់ផ្គង់ប្រេងឥន្ធនៈជាមួយក្រុមហ៊ុនកម្ពុជាតេលា ដើម្បីទទួលការផ្គត់ផ្គង់ប្រេង ផ្អែកតាមកិច្ចសន្យាផ្គត់ផ្គង់ប្រេង ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤។ ក្រោយពេលចុះកិច្ចសន្យាទាំងពីរខាងលើរួចហើយ ក្រុមហ៊ុន [redacted] បានផ្គត់ផ្គង់ប្រេងឥន្ធនៈទៅឲ្យឈ្មោះ [redacted] ច័ន្ទវាសនា និងប្រពន្ធឈ្មោះ [redacted] ភក្ដី តាមរយៈការបញ្ជាទិញ និងដោយការទិញជំពាក់។ រាល់ការបញ្ជាទិញ ចុងចម្លើយឈ្មោះ [redacted] ច័ន្ទវាសនា និងប្រពន្ធឈ្មោះ [redacted] ភក្ដី បានជំពាក់ប្រាក់ថ្លៃប្រេងជាបន្តបន្ទាប់ រហូតបំណុលបានកើនឡើងដល់ចំនួន ១០៧.១២៥,១៤ (ដប់ម៉ឺនប្រាំពីរពាន់មួយរយម្ភៃប្រាំដុល្លារ និងដប់បួនសេន) ផ្អែកតាមកំណត់ហេតុទូទាត់បំណុល ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០-១៤។ ស្របតាមកំណត់ហេតុនេះ ចុងចម្លើយសន្យាសងផ្ដាច់បំណុលទាំងមូលត្រឹម ខែមីនា ឆ្នាំ២០១៥។ ការដែលសហចុងចម្លើយបានសន្យាសងផ្ដាច់តាមកំណត់ហេតុទូទាត់បំណុលនេះ គឺមិនបានអនុវត្តឡើយ ដោយគ្រាន់តែបានសងរំលោះបានតែចំនួន ៧.១២៥,១៤ (ប្រាំពីរពាន់មួយរយម្ភៃប្រាំដុល្លារ និងដប់បួនសេន)ប៉ុណ្ណោះ។ រហូតដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ សហចុងចម្លើយបានសន្យាសងបន្តទៀតលើប្រាក់នៅសល់ចំនួន ១០០.០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក ដោយសន្យាសងរំលោះក្នុងមួយខែ ២.០០០ (ពីរពាន់)ដុល្លារអាមេរិក រហូតដល់សងបំណុលចប់សព្វគ្រប់ដូចមានក្នុងកិច្ចសន្យាទូទាត់បំណុល ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ជាសម្អាង ក៏ប៉ុន្តែ សហចុងចម្លើយសងបានតែចំនួន ៤.០០០(បួនពាន់) ដុល្លារអាមេរិក ហើយក៏លះបង់ការសងទាំងស្រុងតាំងពីឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន។ សព្វថ្ងៃសហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ៩៦.០០០ (ប្រាំបួនម៉ឺនប្រាំមួយពាន់) ដុល្លារអាមេរិក។ ចុងចម្លើយឈ្មោះ [redacted] ជាន្ទីដែលត្រូវជាម្ដាយរបស់ឈ្មោះ [redacted] ច័ន្ទវាសនា និងប្រពន្ធឈ្មោះ [redacted] ភក្ដី បានចូលរួមដោះស្រាយសងបំណុលដោយសាមគ្គី ហើយក៏បានធ្វើការធានាអះអាងថា ក្នុងករណីមិនបានសងបំណុលតាមការអះអាង

ក្នុងកិច្ចសន្យាទូទាត់សងបំណុល ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ទេ ខ្លួននឹងស្ម័គ្រចិត្តលក់អចលនវត្ថុ ដែលមានប័ណ្ណកម្មសិទ្ធិលេខរ.គ០០២២៥៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៧ ដែលមានទីតាំងស្ថិតនៅឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ដើម្បីយកប្រាក់មកទូទាត់សងបំណុល។

**៣.ចំណុចវិវាទ៖ គ្មាន ។**

**<u>សំអាងហេតុ ៖</u>**

-តាមសេចក្តីថ្លែងការណ៍របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ផាន្នី បានបញ្ជាក់ថា៖ កូនក្តីរបស់ខ្លួនត្រូវជាម្តាយរបស់សហចុងចម្លើយឈ្មោះ [redacted] ច័ន្ទវាសនា និងឈ្មោះ [redacted] ភក្តី កូនក្តីខ្លួនពុំមែនជាអ្នកមានទំនាក់ទំនងជំពាក់ប្រាក់ក្រុមហ៊ុន [redacted] ដែលជាដើមចោទផ្ទាល់នោះទេ ប៉ុន្តែ ក្នុងនាមជាម្តាយបានសុខចិត្តចូលខ្លួនមកដោះស្រាយបំណុលរបស់កូនដែលបានជំពាក់ដើមចោទតាមនីតិវិធីច្បាប់។ ប៉ុន្តែ ដើមចោទក្រុមហ៊ុន [redacted] ដែលមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិពុំបានចូលខ្លួនមកដោះស្រាយក្នុងនីតិវិធីច្បាប់ទាំងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះឡើយ នេះបញ្ជាក់ឱ្យឃើញថា ភាគីដើមចោទបានលះបង់នូវសិទ្ធិរបស់ខ្លួនក្នុងការប្តឹងទាមទារប្រាក់ពីកូនក្តីរបស់ខ្លួនតាមផ្លូវច្បាប់។ ហេតុនេះ ខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ សូមស្នើសុំឱ្យតុលាការពិចារណាអំពីអវត្តមានរបស់ភាគីដើមចោទ ដោយគ្មានមូលហេតុនេះ ដោយស្នើសុំឱ្យតុលាការប្រានចោទនិងលើកពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ របស់ដើមចោទ ទុកជាអសាបង់ ស្របតាមបញ្ញត្តិមាត្រា២០០នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-តាមសេចក្តីថ្លែងការណ៍របស់លោកស្រី [redacted] ផាន្នី ជាចុងចម្លើយ បានបញ្ជាក់ថា៖ ខ្លួនត្រូវជាម្តាយរបស់ឈ្មោះ [redacted] ច័ន្ទវាសនា និងឈ្មោះ [redacted] ភក្តី ដែលត្រូវជាកូនបំណុលរបស់ក្រុមហ៊ុន [redacted] ផ្ទាល់ ប៉ុន្តែ ក្នុងនាមជាម្តាយខ្លួនសុខចិត្តចូលមកដោះស្រាយជំនួសបំណុលរបស់កូនទាំងពីរនាក់នេះ ជាមួយនឹងក្រុមហ៊ុនកម្ពុជាគេលាតាមផ្លូវច្បាប់។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ តុលាការបានកោះអញ្ជើញត្រឹមត្រូវតាមនីតិវិធីច្បាប់រួចហើយ ប៉ុន្តែ សាមីខ្លួនពុំបានចូលខ្លួនតាមការកំណត់ឡើយដោយគ្មានមូលហេតុ។

សហចុងចម្លើយឈ្មោះ [redacted] ច័ន្ទវាសនា និងឈ្មោះ [redacted] ភក្តី អវត្តមានដោយគ្មានមូលហេតុ ប៉ុន្តែសហចុងចម្លើយទាំងពីររូបនេះ បានទទួលដំណឹងអំពីការកោះហៅរបស់តុលាការតាមនីតិវិធីច្បាប់រួចហើយដោយបានឱ្យម្តាយឈ្មោះ [redacted] ផាន្នី ជាចុងចម្លើយផងនោះ ចូលមកដោះស្រាយជាមួយនឹងដើមចោទជំនួស។

-តាមលិខិតអញ្ជើញ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២១ និងតាមរបាយការណ៍បញ្ជូនរបស់លោកក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ ដែលជាក្រឡាបញ្ជីកាន់សំណុំរឿង បានបញ្ជាក់ថា លោក [redacted] ដែលជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានទទួលដំណឹងអំពីការកោះអញ្ជើញនេះដោយផ្ទាល់រួចហើយ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១១ និង៥៧នាទី ប៉ុន្តែ សាមីខ្លួន ពុំបានចូលខ្លួន តាមការកំណត់ឡើយ ដោយគ្មានមូលហេតុ។



Scanned with CamScanner

-ការមិនចូលខ្លួនរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ទាំងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ និងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់របស់តុលាការ ដោយគ្មានមូលហេតុបែបនេះ តុលាការចាត់ទុកថា ដើមចោទបានបោះបង់ចោលនូវការទាមទាររបស់ខ្លួនវិញហើយ។ ហេតុនេះ តុលាការនឹងសម្រេចសេចក្តីតទៅទៀតពុំបានឡើយ ចំណុចនេះ មានចែងច្បាស់ក្នុងមាត្រា ២០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-ប្រាក់ប្រដាប់ក្តីដែលអ្នកដាក់ពាក្យសុំ បានបង់រួចនោះ គប្បីសម្រេចរឹបអូស ទុកជាសម្បត្តិរដ្ឋ ។

**សេចក្តីសម្រេចចុងក្រោយ ៖**

**១.ច្រានចោល**នូវពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ របស់ដើមចោទក្រុមហ៊ុន[redacted] មានទីស្នាក់ការផ្ទះលេខ [redacted] ដែលមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ជាអសារបង់។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះ បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខចុងចម្លើយឈ្មោះ [redacted]ជាន្ទី និងមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ,កំបាំងមុខសហចុងចម្លើយឈ្មោះ [redacted] ច័ន្ទវាសនា, [redacted]ភក្តី និងកំបាំងមុខលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ទុកសិទ្ធិឱ្យប្តឹងទាស់ក្នុងរយៈពេល ០២(ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីសាលក្រមនេះ និងបន្ថែមរយៈពេល ០១ (មួយ)ខែ ទៀត សម្រាប់ប្តឹងឧទ្ធរណ៍ គិតចាប់ពីពេលផុតកំណត់ប្តឹងទាស់តទៅ ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និង ត្រា** [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

តាកែវ ,ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]